ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ

លេខ: ០០៤ ស.ជ.ណ

# សេចក្តីណែនាំ
# ស្តីពី
# បែបបទ នីតិវិធី នៃការជ្រើសរើសមេភូមិ ការចូលកាន់តំណែង ការផ្លាស់ប្តូរមេភូមិ ការតែងតាំង ជំនួយការមេភូមិ និង តួនាទី ភារកិច្ច របៀបរបបធ្វើការងាររបស់ភូមិ

យោងតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ អនុក្រឹត្យស្តីពីការផ្ទេរមុខងារ អំណាច តួនាទី និងភារកិច្ចទៅឱ្យក្រុមប្រឹក្សាឃុំ សង្កាត់ និងយោងតាមការសំរេចនៃកិច្ចប្រជុំគណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់លើកទី ២១ កាលពីថ្ងៃទី ០១ ខែ មីនា ឆ្នាំ ២០០៦ ក្រសួងមហាផ្ទៃសូមធ្វើការណែនាំស្តីពីបែបបទ នីតិវិធីនៃការជ្រើសរើសមេភូមិ ការចូលកាន់តំណែង ការផ្លាស់ប្តូរមេភូមិ ការតែងតាំងជំនួយការមេភូមិ និងតួនាទី ភារកិច្ច របៀបរបបធ្វើការងាររបស់ភូមិ ដូចខាងក្រោម :

## ១. អំពីភូមិ

ភូមិ មិនមែនជាថ្នាក់រដ្ឋបាលដែលបានចែងក្នុងរដ្ឋធម្មនុញ្ញឡើយ ។

ភូមិ គឺជាកន្លែងប្រមូលផ្តុំដោយផ្ទះ និងគ្រួសារប្រជាពលរដ្ឋជាច្រើន ។ ភូមិជាច្រើនរួមផ្តុំគ្នាបង្កើតបានឃុំ ឬសង្កាត់មួយ ។

ភូមិនីមួយៗ ត្រូវគ្រប់គ្រងដោយមេភូមិម្នាក់ អមដោយអនុប្រធានភូមិម្នាក់ និងសមាជិកភូមិម្នាក់ជាជំនួយការ ។

## ២. បែបបទ និង នីតិវិធីនៃការជ្រើសរើសមេភូមិ

អនុលោមតាមមាត្រា ៣០ និងមាត្រា ៨៦ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងអាណត្តិទី១នេះ ត្រូវធ្វើការជ្រើសរើសមេភូមិនៅគ្រប់ភូមិទាំងអស់ដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ។

ការរៀបចំជ្រើសរើសមេភូមិ ត្រូវធ្វើឡើងតែនៅភូមិណាដែលក្រសួងមហាផ្ទៃបានទទួលស្គាល់ជាផ្លូវការ ។

ផ្អែកតាមសេចក្តីណែនាំនេះ ក្រុមប្រឹក្សាឃុំ សង្កាត់នីមួយៗ ត្រូវចាត់ឱ្យមេឃុំ ចៅ

សង្កាត់របស់ខ្លួន ធ្វើសេចក្តីរាយការណ៍អំពីឈ្មោះភូមិដែលក្រសួងមហាផ្ទៃបានទទួលស្គាល់ជាផ្លូវការ ។ ដើម្បីជ្រើសរើសមេភូមិសំរាប់ភូមិនីមួយៗ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវអនុវត្តតាមនីតិវិធីដូចខាងក្រោម ÷

**ក**-ក្រុមប្រឹក្សាឃុំ សង្កាត់នីមួយៗត្រូវចាត់ឱ្យមេឃុំ ចៅសង្កាត់ ជំទប់ ចៅសង្កាត់រងរបស់ខ្លួន រៀបចំជ្រើសរើសបេក្ខជនមេភូមិយ៉ាងតិច ០៣ រូប សំរាប់ភូមិនីមួយៗក្នុងឃុំ សង្កាត់របស់ខ្លួន ។

**ខ**-បេក្ខជនមេភូមិ គឺជាប្រជាពលរដ្ឋខ្មែរទាំងពីរភេទ ដែលមានលក្ខណៈសម្បត្តិដូចខាងក្រោម ÷

- មានសញ្ជាតិខ្មែរ
- មានឈ្មោះក្នុងបញ្ជីឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់ដែលសាមីខ្លួនកំពុងរស់នៅ
- មានអាយុយ៉ាងតិច ២៥ ឆ្នាំ គិតត្រឹមថ្ងៃដាក់ស្នើបេក្ខជន
- ចេះអាន និងចេះសរសេរអក្សរខ្មែរ
- មានទីលំនៅអចិន្ត្រៃយ៍ក្នុងភូមិដែលបានដាក់ស្នើបេក្ខជននេះ យ៉ាងតិច ០៦ ខែជាប់ៗគ្នា ។

**គ**-មេឃុំ ចៅសង្កាត់ ជំទប់ ចៅសង្កាត់រង ត្រូវពិគ្រោះពិភាក្សាគ្នាខិតខំជ្រើសរើសឱ្យមានស្ត្រីសំរាប់ជាបេក្ខជនមេភូមិ នៅភូមិនានានៃឃុំ សង្កាត់របស់ខ្លួន ។

**ឃ**-ក្រោយពីបានរៀបចំបេក្ខជនសំរាប់ភូមិនីមួយៗរួចហើយ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវរៀបចំអនុម័តបង្កើតគណៈកម្មការបោះឆ្នោតដែលមានសមាជិកយ៉ាងច្រើនត្រឹម ០៧រូប ដោយមានស្មៀនឃុំ សង្កាត់ចូលរួមផងដែរ ។ គណៈកម្មការបោះឆ្នោត ត្រូវរៀបចំសន្លឹកឆ្នោតសំរាប់ភូមិនីមួយៗ ។ សន្លឹកឆ្នោតសំរាប់ភូមិនីមួយៗ ត្រូវប្រើក្រដាសពណ៌ស ដែលមានទំហំប៉ុនគ្នា ដោយសរសេរនូវឈ្មោះបេក្ខជន (សរសេរដោយដៃ ឬដោយម៉ាស៊ីនអង្គុលីលេខ ឬដោយកុំព្យូទ័រ) ដែលបានដាក់ស្នើដោយមេឃុំ ចៅសង្កាត់ ជំទប់ ចៅសង្កាត់រង ទៅតាមលំដាប់អក្សរនៃឈ្មោះរបស់បេក្ខជនម្នាក់ៗ ។ សន្លឹកឆ្នោតសំរាប់ភូមិនីមួយៗនោះ ត្រូវរៀបចំឱ្យមានចំនួនស្មើនឹងចំនួនសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់សាមី ។ សន្លឹកឆ្នោតសំរាប់បេក្ខជននៃភូមិនីមួយៗ ត្រូវមានត្រារបស់ឃុំ សង្កាត់ដែលបោះនៅលើខ្នងនៃសន្លឹកឆ្នោត ។

**ង**-បន្ទាប់ពីបានរៀបចំសន្លឹកឆ្នោតតាមភូមិនីមួយៗចំណុះឃុំ សង្កាត់ របស់ខ្លួនរួចហើយ គណៈកម្មការបោះឆ្នោត តាមរយៈមេឃុំ ចៅសង្កាត់ ត្រូវដាក់ជូនកិច្ចប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់របស់ខ្លួន ដើម្បីរៀបចំបោះឆ្នោតជ្រើសរើសម្តងមួយភូមិៗក្នុងរយៈពេលមិន

ឱ្យលើសពី ០៧ថ្ងៃ បន្ទាប់ពីថ្ងៃដាក់ស្នើបេក្ខជននោះ ។

**ច**-មុនចាប់ផ្តើមបោះឆ្នោតជ្រើសរើសមេភូមិ អធិបតីនៃអង្គប្រជុំត្រូវធ្វើសេចក្តីរាយការណ៍ជូនកិច្ចប្រជុំក្រុមប្រឹក្សារបស់ខ្លួន អំពីគោលការណ៍សំខាន់ៗនៃការបោះឆ្នោតជ្រើសរើសមេភូមិ រួចហើយត្រូវប្រគល់ភារកិច្ចជូនគណៈកម្មការបោះឆ្នោតដើម្បីរៀបចំនីតិវិធីដូចខាងក្រោម ÷

- សន្លឹកឆ្នោតសំរាប់ភូមិនីមួយៗ ត្រូវរៀបចំឱ្យមានចំនួនស្មើនឹងសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ។ សន្លឹកឆ្នោតសំរាប់ភូមិនីមួយៗ ត្រូវរៀបចំឱ្យដូចៗគ្នានូវទំរង់ ទំហំ និងឈ្មោះបេក្ខជន ។

- រាយការណ៍ជូនកិច្ចប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់របស់ខ្លួន អំពីឈ្មោះបេក្ខជនសំរាប់ភូមិនីមួយៗ ។

- សមាជិកក្រុមប្រឹក្សាម្នាក់ៗមានសិទ្ធិទទួលបានសន្លឹកឆ្នោតមួយសន្លឹកសំរាប់ភូមិមួយដែលបានចែកជូនក្នុងពេលបោះឆ្នោត ។

- សមាជិកក្រុមប្រឹក្សាម្នាក់ត្រូវគូសជ្រើសយកបេក្ខជនដែលខ្លួនគាំទ្រតែម្នាក់ប៉ុណ្ណោះលើសន្លឹកឆ្នោតដែលបានចែកជូនដោយគណៈកម្មការបោះឆ្នោត ។

- សន្លឹកឆ្នោតមិនបានការជាសន្លឹកឆ្នោតដែល :

  + មិនមែនជាសន្លឹកឆ្នោតដែលបានចែកជូនដោយគណៈកម្មការបោះឆ្នោត
  + គ្មានត្រារបស់ឃុំ សង្កាត់
  + គូសគាំទ្របេក្ខជនលើសពីម្នាក់
  + មិនមានគំនូសគាំទ្របេក្ខជនណាម្នាក់
  + មានសញ្ញាដែលធ្វើឱ្យគេស្គាល់អ្នកបោះឆ្នោត
  + រហែក ឬខូច
  + មានគំនូស តែគណៈកម្មការរៀបចំការបោះឆ្នោតមិនអាចកំណត់បានថាគាំទ្របេក្ខជនណាមួយ ។

**ឆ**-បន្ទាប់ពីបានណែនាំពីគោលការណ៍ នៃការបោះឆ្នោតជ្រើសរើសរួចរាល់ហើយ គណៈកម្មការបោះឆ្នោតត្រូវចែកសន្លឹកឆ្នោតជូនសមាជិកក្រុមប្រឹក្សាដែលមានវត្តមានក្នុងកិច្ចប្រជុំ ដើម្បីបោះឆ្នោតជ្រើសរើសមេភូមិម្តងមួយភូមិៗ ។

**ជ**-ក្រោយពីសមាជិកក្រុមប្រឹក្សាគ្រប់ៗរូប ដែលមានវត្តមានក្នុងកិច្ចប្រជុំបានបោះឆ្នោតជ្រើសរើសរួចរាល់អស់ហើយ គណៈកម្មការបោះឆ្នោតត្រូវធ្វើការរាប់សន្លឹកឆ្នោតភូមិដែលបានបោះឆ្នោតនោះនៅចំពោះមុខអង្គប្រជុំ ដោយកត់ត្រាលទ្ធផលនៃការបោះឆ្នោត

ជ្រើសរើសមេភូមិនៃភូមិនីមួយៗនោះ នៅលើក្តារខៀន ឬផ្ទាំងក្រដាសស រួចហើយអធិបតីនៃអង្គប្រជុំត្រូវប្រកាសលទ្ធផលនៃការបោះឆ្នោត បន្ទាប់ពីការរាប់សន្លឹកឆ្នោតហើយភ្លាម ។

**ឈ**-បន្ទាប់មកអធិបតីនៃអង្គប្រជុំ ត្រូវចាត់ឱ្យគណៈកម្មការបោះឆ្នោត រៀបចំបោះឆ្នោតជ្រើសរើសមេភូមិផ្សេងទៀតដែលនៅសល់ជាបន្តបន្ទាប់រហូតគ្រប់ចំនួនភូមិដែលបានទទួលស្គាល់ជាផ្លូវការ ។

**ញ**- បេក្ខជនដែលជាប់ឆ្នោត គឺជាបេក្ខជនដែលមានសម្លេងឆ្នោតគាំទ្រច្រើនជាងគេ ហើយសម្លេងគាំទ្រនោះ ត្រូវមានចំនួនលើសពីពាក់កណ្តាល នៃសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ទាំងមូល ។

**ដ**-ក្នុងពេលរាប់សន្លឹកឆ្នោត ប្រសិនបេក្ខជនណាដែលមានសម្លេងឆ្នោតស្មើគ្នា សម្លេងរបស់អធិបតីនៃអង្គប្រជុំមានឧត្តមានុភាព ។ ក្នុងករណីសម្លេងស្មើគ្នានោះជាបេក្ខ-ជនបុរស និងបេក្ខជនស្ត្រី បេក្ខជនស្ត្រីត្រូវបានជាប់ឆ្នោតជាមេភូមិ ។

**ឋ**-ចំពោះបេក្ខជនភូមិណាដែលមិនបានទទួលសម្លេងឆ្នោតគាំទ្រលើសពីពាក់កណ្តាលនៃសមាជិកក្រុមប្រឹក្សាទាំងមូល អធិបតីនៃអង្គប្រជុំត្រូវចាត់ឱ្យមេឃុំ ចៅសង្កាត់ ជំទប់ចៅសង្កាត់រងដាក់ស្នើបេក្ខជនជាថ្មីសំរាប់ភូមិនោះ ទៅតាមបែបបទ នីតិវិធី ដូចមានចែងក្នុងចំណុច **ក ខ គ** និង **ឃ** ។

ក្នុងករណីនេះ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវកោះប្រជុំដើម្បីបោះឆ្នោតជ្រើសរើសលើបេក្ខជនមេភូមិនោះជាលើកទី២ ទៅតាមបែបបទ នីតិវិធីនៃការបោះឆ្នោតចាប់ពីចំណុច **ខ** ដល់ចំណុច **ដ** ខាងលើ ក្នុងរយៈពេលយ៉ាងយូរ០៧ថ្ងៃ បន្ទាប់ពីថ្ងៃបោះឆ្នោតលើកទី១ ។

នៅក្នុងការបោះឆ្នោតលើកទី២នេះ ប្រសិនបើបេក្ខជននៅតែមិនបានទទួលសម្លេងឆ្នោតគាំទ្រលើសពីពាក់កណ្តាលនៃសមាជិកក្រុមប្រឹក្សាទាំងមូលទៀត អធិបតីនៃអង្គប្រជុំត្រូវចាត់ឱ្យមេឃុំ ចៅសង្កាត់ជ្រើសយកតែបេក្ខជនពីររូបដែលមានសម្លេងឆ្នោតគាំទ្របន្តបន្ទាប់គ្នាមកធ្វើការបោះឆ្នោតជ្រើសរើសសារឡើងវិញភ្លាម ។ ក្នុងការបោះឆ្នោតលើកចុងក្រោយនេះ បើគ្មានបេក្ខជនណាម្នាក់បានទទួលសម្លេងឆ្នោតគាំទ្រគ្រប់គ្រាន់ដូចមានចែងក្នុងចំណុច **ញ** ខាងលើនេះទេ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវ :

- សំរេចជ្រើសយកបេក្ខជនជាស្ត្រីធ្វើជាមេភូមិ បើក្នុងចំណោមបេក្ខជនទាំងពីរខាងលើនេះមានម្នាក់ជាស្ត្រី
- សំរេចជ្រើសយកបេក្ខជនដែលមានអាយុចាស់ជាងធ្វើជាមេភូមិ បើសិនជាបេក្ខជនទាំងពីរខាងលើនេះជាបុរស ។

បេក្ខជនមេភូមិទាំងឡាយណាដែលក្រុមប្រឹក្សាឃុំ សង្កាត់បានបោះឆ្នោតជ្រើសរើស

រួចហើយ មេឃុំ ចៅសង្កាត់ត្រូវចេញសេចក្ដីសំរេចតែងតាំងមេភូមិនីមួយៗនោះក្នុងរយៈពេល ០៧ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃដែលក្រុមប្រឹក្សាឃុំ សង្កាត់បានបោះឆ្នោត ។

## ៣. អំពីការតែងតាំងជំនួយការមេភូមិ

អនុលោមតាមមាត្រា ៣០ និង មាត្រា ៨៦ នៃច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ មេឃុំ ចៅសង្កាត់ត្រូវណែនាំមេភូមិនីមួយៗដែលបានទទួលការតែងតាំងជាផ្លូវការ រួចហើយនោះ អោយធ្វើការដាក់បេក្ខជនជំនួយការរបស់ខ្លួនជាអនុប្រធាន និងសមាជិកភូមិ រួចហើយលើកសំណើដល់មេឃុំ ចៅសង្កាត់សាមីដើម្បីដាក់ជូនក្រុមប្រឹក្សាឃុំ សង្កាត់របស់ខ្លួន ពិនិត្យ និងអនុម័តក្នុងរយៈពេលយ៉ាងយូរ ០៧ ថ្ងៃ បន្ទាប់ពីថ្ងៃតែងតាំងមេភូមិនោះជាផ្លូវការ ។

ក្នុងការរៀបចំបេក្ខជនអនុប្រធាន និងសមាជិកភូមិនីមួយៗ មេភូមិ និងមេឃុំ ចៅសង្កាត់ ត្រូវរៀបចំឱ្យមានបេក្ខជនស្ត្រីយ៉ាងហោចណាស់ម្នាក់ សំរាប់មុខតំណែងអនុប្រធានភូមិ ឬសមាជិកភូមិ ចំពោះភូមិទាំងឡាយណាដែលមានមេភូមិជាបុរស ។

បេក្ខជនសំរាប់មុខតំណែងអនុប្រធាន និងសមាជិកភូមិ មានលក្ខណៈសម្បត្តិដូចគ្នានឹងមេភូមិ ដូចបានកំណត់ក្នុងចំណុច ខ នៃចំណុចទី២ ខាងលើ ។

ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវអនុម័តដោយលើកដៃ លើបេក្ខជនអនុប្រធាន និងសមាជិកភូមិនីមួយៗចំណុះឃុំ សង្កាត់របស់ខ្លួន តាមសម្លេងភាគច្រើននៃសមាជិកក្រុមប្រឹក្សាទាំងមូល ក្នុងរយៈពេល ០៥ថ្ងៃ បន្ទាប់ពីថ្ងៃទទួលបេក្ខជននេះ ។

ក្នុងពេលអនុម័ត ប្រសិនបើមានសម្លេងស្មើគ្នា សម្លេងអធិបតីនៃអង្គប្រជុំមានឧត្តមានុភាព ។ ផ្ទុយទៅវិញប្រសិនបើបេក្ខជនសំរាប់មុខតំណែងជាអនុប្រធានភូមិ ឬសមាជិកភូមិនៃភូមិណាមួយដែលមិនបានទទួលការគាំទ្រពីក្រុមប្រឹក្សាឃុំ សង្កាត់ទេនោះ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវចាត់ឱ្យមេឃុំ ចៅសង្កាត់របស់ខ្លួនពិគ្រោះពិភាក្សាជាមួយជំទប់ចៅសង្កាត់រង ដើម្បីណែនាំមេភូមិឱ្យដាក់ស្នើបេក្ខជនជាលើកទី២ ក្នុងរយៈពេល ០៥ថ្ងៃយ៉ាងយូរ ។

ក្នុងករណីនេះ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវកោះប្រជុំវិសាមញ្ញដើម្បីពិនិត្យ និងអនុម័តនៅលើបេក្ខជនជំនួយការនោះជាលើកទី២ ក្នុងរយៈពេលយ៉ាងយូរ ០៧ថ្ងៃ បន្ទាប់ពីថ្ងៃដែលបានដាក់ស្នើបេក្ខភាព ។

លើកទី២នេះ ប្រសិនបើបេក្ខជនដែលបានដាក់ស្នើនេះនៅតែមិនបានទទួលការគាំទ្រពីក្រុមប្រឹក្សាឃុំ សង្កាត់ ដោយសម្លេងភាគច្រើននៃសមាជិកក្រុមប្រឹក្សាទាំងមូលទេនោះ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវចាត់ឱ្យបោះឆ្នោតគាំទ្រម្ដងទៀត ដោយសម្លេងភាគ

ច្រើននៃសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ដែលបានចូលរួម ។

បេក្ខជនជំនួយការមេភូមិទាំងឡាយណាដែលក្រុមប្រឹក្សាឃុំ សង្កាត់បានអនុម័តយល់ព្រមរួចហើយ មេឃុំ ចៅសង្កាត់ត្រូវចេញសេចក្តីសំរេចតែងតាំងជំនួយការមេភូមិនីមួយៗ នោះក្នុងរយៈពេល ០៧ថ្ងៃ យ៉ាងយូរបន្ទាប់ពីថ្ងៃដែលក្រុមប្រឹក្សាឃុំ សង្កាត់បានអនុម័ត ។

ប្រធាន អនុប្រធាន និងសមាជិកភូមិក្នុងមុខតំណែងត្រូវបានបន្តការងាររហូតដល់មានការតែងតាំងមេភូមិ អនុប្រធានភូមិ និងសមាជិកភូមិថ្មីមកជំនួស ។

ប្រធាន អនុប្រធាន និងសមាជិកភូមិក្នុងមុខតំណែង អាចត្រូវជ្រើសរើសជាបេក្ខជនសំរាប់មុខតំណែងមេភូមិ ឬអនុប្រធានភូមិ ឬសមាជិកភូមិបាន ឱ្យតែជននោះមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ស្របតាមការណែនាំនេះ ។

## ៤. អាណត្តិការងារ និង ការបាត់បង់មុខតំណែង

មេភូមិ អនុប្រធានភូមិ និងសមាជិកភូមិ មិនត្រូវបានកំណត់អាណត្តិការងារឡើយ។

មេភូមិ អនុប្រធានភូមិ និងសមាជិកភូមិ ត្រូវបាត់បង់ពីមុខតំណែងក្នុងករណីណាមួយដូចខាងក្រោម ៖

- សាមីខ្លួនទទួលមរណភាព
- សាមីខ្លួនដាក់ពាក្យសុំលាឈប់ពីមុខតំណែងជាលាយល័ក្ខអក្សរ
- សាមីខ្លួនបាត់បង់សម្បទាវិជ្ជាជីវៈដោយមានលិខិតបញ្ជាក់ពីភ្នាក់ងារមានសមត្ថកិច្ច
- សាមីខ្លួនត្រូវបានលុបឈ្មោះចេញពីបញ្ជីឈ្មោះអ្នកបោះឆ្នោតនៃឃុំ សង្កាត់របស់ខ្លួន
- សាមីខ្លួនត្រូវតុលាការផ្តន្ទាទោសពីបទឧក្រិដ្ឋ ឬមជ្ឈិមណាមួយ
- សាមីខ្លួនផ្លាស់ទីលំនៅទៅភូមិផ្សេង
- សាមីខ្លួនមានកំហុសឆ្គងក្នុងការងារ ហើយត្រូវបញ្ឈប់ពីមុខតំណែងដោយក្រុមប្រឹក្សាឃុំ សង្កាត់របស់ខ្លួន ។

មេភូមិ ឬអនុប្រធានភូមិ ឬសមាជិកភូមិ ដែលអនុវត្តផ្ទុយពីតួនាទី ភារកិច្ច និងរបៀបរបបការងារដូចមានចែងក្នុងចំណុចទី ៥ នៃសេចក្តីណែនាំនេះ ត្រូវចាត់ទុកថាមានកំហុសឆ្គងក្នុងការងារ ។

ក្នុងករណីមានមេភូមិ ឬអនុប្រធានភូមិ ឬសមាជិកភូមិណាមួយ ដែលបានប្រព្រឹត្តខុសឆ្គងក្នុងការងារ មេឃុំ ចៅសង្កាត់សាមី ត្រូវធ្វើការណែនាំជាលាយល័ក្ខអក្សរឱ្យសាមីខ្លួនកែលំអចំណុចខុសឆ្គងទាំងនោះ និងត្រូវធ្វើសេចក្តីរាយការណ៍ជូនក្នុងកិច្ចប្រជុំបន្ទាប់របស់ក្រុមប្រឹក្សាឃុំ សង្កាត់របស់ខ្លួន ។ ក្នុងករណីដែលបានទទួលការណែនាំហើយ ប៉ុន្តែសាមីខ្លួននៅតែប្រព្រឹត្តខុសឆ្គងបន្តទៀតនោះ មេឃុំ ចៅសង្កាត់ត្រូវធ្វើសេចក្តីរាយការណ៍

ជូនក្រុមប្រឹក្សាឃុំ សង្កាត់ ហើយក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវកោះអញ្ជើញសាមីខ្លួនអោយមកទទួលការណែនាំនៅក្នុងកិច្ចប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់ ដោយមានចុះក្នុងកំណត់ហេតុនៃកិច្ចប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់ដើម្បីឱ្យសាមីខ្លួនធ្វើការកែលំអកំហុសឆ្គង ។ ក្រោយពីបានទទួលការណែនាំពីក្រុមប្រឹក្សាឃុំ សង្កាត់រួចហើយ ប្រសិនបើសាមីខ្លួនមិនព្រមរាងចាល មេឃុំ ចៅសង្កាត់ត្រូវធ្វើសេចក្តីរាយការណ៍ជូនក្រុមប្រឹក្សាឃុំ សង្កាត់ និងស្នើសុំឱ្យក្រុមប្រឹក្សាឃុំ សង្កាត់សំរេចអនុម័ត បញ្ឈប់ជននោះពីមុខតំណែងតាមសម្លេងភាគច្រើននៃក្រុមប្រឹក្សាឃុំ សង្កាត់ទាំងមូល ។

ក្នុងករណីមានមេភូមិ ឬអនុប្រធានភូមិ ឬសមាជិកភូមិណាម្នាក់ត្រូវបានបាត់បង់ពីមុខតំណែងតាមករណីណាមួយខាងលើនេះ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវចាត់ឱ្យធ្វើការជ្រើសរើសបេក្ខជនសំរាប់កន្លែងដែលទំនេរនោះ ដើម្បីដាក់ជូនក្រុមប្រឹក្សាឃុំ សង្កាត់ពិនិត្យអនុម័ត ក្នុងរយៈពេល ០៧ថ្ងៃយ៉ាងយូរ ស្របទៅតាមបែបបទ និងនីតិវិធី ដូចមានចែងក្នុងចំណុចទី២ និងចំណុចទី៣ នៃសេចក្តីណែនាំនេះ ។

## ៥. តួនាទី ភារកិច្ច និង របៀបរបបការងាររបស់ភូមិ

ផ្អែកតាមមាត្រា ៣១ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និងមាត្រា ២៣ ២៤ ២៥ ២៦ ២៧ ២៨ និងមាត្រា ២៩ នៃអនុក្រឹត្យស្តីពីការផ្ទេរវិមជ្ឈការអំណាច តួនាទី និងភារកិច្ចទៅឱ្យក្រុមប្រឹក្សាឃុំ សង្កាត់ មេភូមិ អនុប្រធានភូមិ និងសមាជិកភូមិត្រូវបានកំណត់តួនាទី ភារកិច្ច និងរបៀបរបបការងារដូចខាងក្រោម ÷

- មេភូមិ ជាតំណាងឱ្យប្រជាពលរដ្ឋទាំងអស់នៅក្នុងភូមិ និងជាខ្សែរយៈចម្បងសំរាប់តភ្ជាប់ទំនាក់ទំនងរវាងភូមិ និងក្រុមប្រឹក្សាឃុំ សង្កាត់ ។

- ក្នុងការអនុវត្តការងារ មេភូមិត្រូវ :

១. បង្កើនការពិគ្រោះយោបល់ ទទួលការណែនាំ និងធ្វើកិច្ចសហប្រតិបត្តិការជាមួយក្រុមប្រឹក្សាឃុំ សង្កាត់របស់ខ្លួន

២. ចូលរួមក្នុងកិច្ចប្រជុំគណៈកម្មាធិការនានារបស់ឃុំ សង្កាត់ នៅពេលដែលក្រុមប្រឹក្សាឃុំ សង្កាត់តម្រូវ ដើម្បីផ្តល់យោបល់អំពីកិច្ចការដែលពាក់ព័ន្ធក្នុងភូមិរបស់ខ្លួនមាន ជាអាទិ៍ :

+ ផ្តល់យោបល់ដល់គណៈកម្មាធិការកិច្ចការភូមិអំពីតម្រូវការនិងផលប្រយោជន៍របស់ភូមិ

+ ផ្តល់យោបល់ដល់គណៈកម្មាធិការកិច្ចការភូមិ អំពីរបៀបបង្កើន និងកសាងសមត្ថភាព និងធនធានរបស់ភូមិ

+ ផ្តល់យោបល់ដល់គណៈកម្មាធិការផែនការអភិវឌ្ឍន៍ និងថវិកា អំពី ៖

- តម្រូវការ និងអាទិភាពរបស់ភូមិ ដើម្បីបញ្ចូលក្នុងថវិកានិងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់
- អនុវត្តថវិកា និងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ក្នុងភូមិរបស់ខ្លួន
- ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តថវិកា និងផែនការអភិវឌ្ឍន៍របស់ឃុំ សង្កាត់ក្នុងភូមិរបស់ខ្លួន ។

- មេភូមិត្រូវធ្វើសេចក្តីរាយការណ៍រាល់បញ្ហាដែលពាក់ព័ន្ធនឹងភូមិរបស់ខ្លួន ដើម្បីដាក់បញ្ចូលក្នុងរបាយការណ៍ប្រចាំឆ្នាំរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ។

- មេភូមិត្រូវទទួលខុសត្រូវអនុវត្តកិច្ចការដែលបានប្រគល់ឱ្យដោយក្រុមប្រឹក្សាឃុំ សង្កាត់របស់ខ្លួន ។

- មេភូមិត្រូវចូលរួមកិច្ចប្រជុំរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងករណីមានសំណូមពរពីក្រុមប្រឹក្សាឃុំ សង្កាត់ ។

- មេភូមិ មិនមានសិទ្ធិអំណាចចុះហត្ថលេខាលើកិច្ចសន្យា ឬការផ្ទេរអំណាច ឬការចាត់ចែងដទៃទៀតក្នុងនាមភូមិបានឡើយ ។

- មេភូមិ អនុប្រធានភូមិ និងសមាជិកភូមិ ត្រូវជួបប្រជុំគ្នាយ៉ាងតិចមួយដងក្នុងមួយខែ ។

- មេភូមិ អនុប្រធានភូមិ និងសមាជិកភូមិ ត្រូវធ្វើការពិគ្រោះឱ្យបានទៀងទាត់ជាមួយប្រជាពលរដ្ឋក្នុងភូមិរបស់ខ្លួន ។

ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវពិភាក្សាជាមួយមេភូមិ ដើម្បីរៀបចំឱ្យមានទីកន្លែងសំរាប់មេភូមិជួបប្រាស្រ័យជាមួយមជ្ឈដ្ឋាននានាតាមភូមិនីមួយៗ ។

ទីកន្លែងនោះ អាចជាទីស្នាក់ការភូមិ ចំពោះកន្លែងដែលមានទីស្នាក់ការភូមិ ។ ចំពោះកន្លែងដែលគ្មានទីស្នាក់ការភូមិ ត្រូវពិគ្រោះពិភាក្សាគ្នា ដើម្បីរកទីកន្លែងសមស្របណាមួយ ដែលអាចជាសាលារៀន វត្តអារាម វិហារសាសនា អគារសាធារណៈ ឬគេហដ្ឋានផ្ទាល់របស់មេភូមិ ។ ការជ្រើសរើសយកកន្លែងទាំងនោះ ត្រូវមានការពិគ្រោះពិភាក្សាឱ្យឯកភាពគ្នាពីក្រុមប្រឹក្សាឃុំ សង្កាត់ មេភូមិ អនុប្រធានភូមិ សមាជិកភូមិ និងត្រូវមានការយល់ព្រមជាមុនពីម្ចាស់ទីកន្លែងទាំងនោះ ។ មេភូមិ និងក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវផ្សព្វផ្សាយទីកន្លែងនោះដល់សាធារណៈជន ។

ទីកន្លែងនោះត្រូវបើកទទួលប្រជាពលរដ្ឋយ៉ាងហោចណាស់មួយថ្ងៃក្នុងមួយសប្តាហ៍។

មេភូមិ ឬអនុប្រធានភូមិ ឬសមាជិកភូមិ ត្រូវមានវត្តមាននៅទីកន្លែងដែលបាន

កំណត់នោះ នាថ្ងៃនោះ ដើម្បីជួបប្រជាពលរដ្ឋ ។

ក្រៅពីការជួបប្រាស្រ័យជាទៀងទាត់ជាមួយប្រជាពលរដ្ឋរបស់ខ្លួននៅទីកន្លែងដែលបានកំណត់នោះ មេភូមិ អនុប្រធានភូមិ និងសមាជិកភូមិ អាចនឹងជួបប្រាស្រ័យផ្ទាល់ជាមួយប្រជាពលរដ្ឋក្នុងភូមិរបស់ខ្លួនជាប្រចាំតាមការចាំបាច់ ។

មេភូមិត្រូវធានាផ្តល់ពត៌មានជាឯកសារជាសាធារណៈដែលពាក់ព័ន្ធនឹងភូមិរបស់ខ្លួនជូនដល់ប្រជាពលរដ្ឋរបស់ខ្លួន ។ ឯកសារពត៌មានទាំងនោះអាចរួមមាន ពត៌មានស្តីពីការប្រជុំរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ផែនការអភិវឌ្ឍន៍ និងថវិកាឃុំ សង្កាត់ ។

មេភូមិ ពុំមានសិទ្ធិអំណាចសំរេចបញ្ហាណាមួយដែលស្ថិតក្នុងសមត្ថកិច្ចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ដោយគ្មានការផ្ទេរអំណាចពីក្រុមប្រឹក្សាឃុំ សង្កាត់ ស្របតាមប្រកាសរបស់ក្រសួងមហាផ្ទៃ ដែលបានអនុម័តយល់ព្រមដោយគណៈកម្មាធិការជាតិគាំទ្រឃុំសង្កាត់បានឡើយ ។

ក្រុមប្រឹក្សាឃុំ សង្កាត់មិនអាចផ្ទេរអំណាចដល់បុគ្គល ឬគណៈកម្មាធិការ ឬអង្គការណាមួយនៅក្នុងភូមិបានឡើយ លើកលែងតែមានការអនុញ្ញាតដែលបានចែងក្នុងប្រកាសរបស់ក្រសួមហាផ្ទៃដែលបានអនុម័តយល់ព្រមដោយគណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់។

ដើម្បីធានាអនុវត្តនូវតួនាទី ភារកិច្ចខាងលើនេះ មេភូមិ អនុប្រធានភូមិ និងសមាជិកភូមិ ត្រូវបានធ្វើការបែងចែកប្រគល់ភារកិច្ចដូចខាងក្រោម ៖

- មេភូមិទទួលខុសត្រូវរួមក្នុងភូមិរបស់ខ្លួន

- អនុប្រធានភូមិទទួលជំនួសមេភូមិ ក្នុងពេលដែលមេភូមិអវត្តមាន ដោយមានមូលហេតុច្បាស់លាស់ ដូចជា មានជម្ងឺ ឬមានបេសកកម្មក្រៅពីឃុំ សង្កាត់សាមី លើសពី ០១ថ្ងៃ។ ក្រៅពីនេះ អនុប្រធានភូមិត្រូវទទួលជួយមេភូមិលើការអនុវត្តគំរោងអភិវឌ្ឍន៍នានាក្នុងភូមិ តាមគំរោងផែនការរបស់ឃុំ សង្កាត់ ។

- សមាជិកភូមិទទួលជួយធ្វើជាលេខាធិការឱ្យមេភូមិ និងទទួលជួយមេភូមិលើការងារស្ថិតិ ការចុះបញ្ជីប្រជាពលរដ្ឋ និងការរក្សាទុកឯកសារនានារបស់ភូមិ ។

ក្រៅពីការងារខាងលើនេះ មេភូមិអាចធ្វើការបែងចែក ប្រគល់ភារកិច្ចដល់អនុប្រធានភូមិ និងសមាជិកភូមិតាមការចាំបាច់ និងធ្វើសេចក្តីរាយការណ៍ជូនមេឃុំ ចៅសង្កាត់សាមី ។

## ៦. អំពីការបង្កើតភូមិថ្មី ការបង្រួម និង ការរំសាយភូមិ

ដើម្បីធានាដល់ការចាត់ចែងការងារ និងកិច្ចអភិវឌ្ឍន៍ឃុំ សង្កាត់ ក្រុមប្រឹក្សាឃុំសង្កាត់អាចលើកសំណើសុំបង្កើតភូមិថ្មី ឬបំបែក ឬរំសាយ និងបង្រួមភូមិ ចំណុះឃុំ

សង្កាត់របស់ខ្លួនបាន ប៉ុន្តែត្រូវផ្អែកលើលក្ខណៈវិនិច្ឆ័យដូចខាងក្រោម ៖

**ក. <u>ការបង្កើតភូមិថ្មី</u> ត្រូវមានលក្ខណៈវិនិច្ឆ័យដូចតទៅ ៖**

- មានលំនៅឋាន និងប្រជាពលរដ្ឋយ៉ាងតិច ១៥០គ្រួសារ ដែលប្រមូលផ្តុំគ្នានៅទីតាំងមួយសមស្រប ហើយដែលលំបាកដាក់បញ្ចូលទៅក្នុងភូមិណាមួយនៃឃុំ សង្កាត់ជាមួយ ឬឃុំ សង្កាត់ដែលជិតខាងជាប់គ្នា
- មិនត្រូវស្ថិតក្នុងទីតាំងដែលច្បាប់ហាមឃាត់
- ត្រូវមានប្រជាពលរដ្ឋលើសពីពាក់កណ្តាលនៃភូមិដែលគ្រោងបង្កើតថ្មីនោះគាំទ្រ
- គ្មានការតវ៉ាពីភូមិ ឬឃុំ សង្កាត់ជិតខាងដែលនៅជាប់គ្នា ។

**ខ. <u>ការបំបែកភូមិ</u> ត្រូវមានលក្ខណៈវិនិច្ឆ័យដូចតទៅ ៖**

- ភូមិដែលស្នើបំបែកនោះ មានប្រជាពលរដ្ឋច្រើនលើសលប់ ឬពិបាកគ្រប់គ្រង
- ក្រោយពេលបំបែកហើយ នៅសល់ចំនួនប្រជាពលរដ្ឋសមស្របយ៉ាងហោចណាស់ស្មើនឹងភូមិដែលបង្កើតថ្មីដែរ
- ត្រូវមានប្រជាពលរដ្ឋលើសពីពាក់កណ្តាលគាំទ្រ
- គ្មានការតវ៉ាពីភូមិ ឬឃុំ សង្កាត់ណាមួយជិតខាងដែលនៅជាប់គ្នា ។

**ឃ. <u>ការរំសាយ និងការបង្រួមភូមិបញ្ចូលគ្នា</u> ត្រូវមានលក្ខណៈវិនិច្ឆ័យដូចខាងក្រោម ៖**

- មានចំនួនលំនៅឋាននិងគ្រួសារប្រជាពលរដ្ឋតិចពេក ឬមានភូមិសាស្ត្ររ៉ាយប៉ាយពិបាកក្នុងការគ្រប់គ្រង និងការអភិវឌ្ឍន៍
- ក្រោយពេលរំសាយ និងបង្រួមបញ្ចូលគ្នាហើយ មានចំនួនប្រជាពលរដ្ឋយ៉ាងហោចណាស់ស្មើនឹងភូមិដែលទើបបង្កើតថ្មី
- ត្រូវមានប្រជាពលរដ្ឋលើសពីពាក់កណ្តាលនៃភូមិដែលត្រូវរំសាយ និង បង្រួមបញ្ចូលគ្នានោះគាំទ្រ
- គ្មានការតវ៉ាពីភូមិ ឬឃុំ សង្កាត់ណាមួយដែលនៅជិតខាងជាប់គ្នា ។

លក្ខណៈសម្បត្តិខាងលើនេះមិនត្រូវយកមកអនុវត្តចំពោះភូមិប្រជាពលរដ្ឋជនជាតិដើមភាគតិចឡើយ ។

មេឃុំ ចៅសង្កាត់នៅពេលដែលពិនិត្យឃើញមានតម្រូវការចាំបាច់ក្នុងការបង្កើតភូមិថ្មី ឬការបំបែក ឬរំសាយ និងបង្រួមភូមិ ត្រូវចាត់ឱ្យមានគណៈកម្មការមួយ ដើម្បីស្រាវជ្រាវ រៀបចំរបាយការណ៍ និងឯកសារផ្សេងៗទៅសុំការសំរេចពីក្រុមប្រឹក្សាឃុំ សង្កាត់ ។

ប្រសិនបើក្រុមប្រឹក្សាឃុំ សង្កាត់សំរេចឯកភាពលើសំណើសុំបង្កើតភូមិថ្មី ឬបំបែក ឬរំសាយភូមិ និងបង្រួមបញ្ចូលគ្នានោះ មេឃុំ ចៅសង្កាត់ត្រូវលើកសំណើទៅអភិបាល

ខេត្ត ក្រុងសាមី ។ ក្រោយពីទទួលបានសំណើ អភិបាលខេត្ត ក្រុងត្រូវចាត់អោយធ្វើការពិនិត្យ និងវាយតំលៃតាមលក្ខណៈវិនិច្ឆ័យខាងលើនេះ ។ ករណីពិនិត្យឃើញថា សំណើនេះមានលក្ខណៈសមស្របហើយ អភិបាលខេត្ត ក្រុងត្រូវសុំការសំរេចពីក្រសួងមហាផ្ទៃ ។ ការបង្កើតភូមិថ្មី ឬការបំបែក ឬការរំសាយ និងការបង្រួមភូមិ ត្រូវធ្វើដោយប្រកាសក្រសួងមហាផ្ទៃ ។

ក្នុងករណីដែលមានហេតុផលគ្រប់គ្រាន់បញ្ជាក់ថា សំណើសុំបង្កើតភូមិថ្មី ឬបំបែក ឬរំសាយ និងបង្រួមភូមិណាមួយដែលមិនស្របតាមលក្ខណៈវិនិច្ឆ័យ និងមិនអនុវត្តតាមបែបបទខាងលើនេះ ក្រសួងមហាផ្ទៃអាចបដិសេធសំណើសុំបង្កើតភូមិថ្មី ឬបំបែក ឬរំសាយ និងបង្រួមភូមិនោះ រួចហើយត្រូវណែនាំអោយរៀបចំសំណើជាថ្មី ឬអាចផ្អាកការបង្កើតភូមិថ្មី ឬការបំបែក ឬការរំសាយ និងបង្រួមភូមិនោះ ដោយភ្ជាប់ជាមួយនូវការណែនាំអំពីវិធានការចាំបាច់នានាក្នុងការលើកកំពស់ប្រសិទ្ធភាពក្នុងការគ្រប់គ្រង និងការអភិវឌ្ឍន៍ភូមិទាំងនោះ ។

យោងតាមសេចក្តីណែនាំនេះ នាយកដ្ឋានរដ្ឋបាលមូលដ្ឋាន អគ្គនាយកដ្ឋានរដ្ឋបាលនៃក្រសួងមហាផ្ទៃ ត្រូវធ្វើការបណ្តុះបណ្តាលកសាងសមត្ថភាពដល់ក្រុមប្រឹក្សាឃុំ សង្កាត់ ដើម្បីអនុវត្តឱ្យបានត្រឹមត្រូវនូវសេចក្តីណែនាំនេះ ។ អភិបាលខេត្ត ក្រុងនីមួយៗត្រូវផ្អែកតាមសិទ្ធិអំណាចដែលបានធ្វើប្រតិភូកម្ម ដូចមានចែងក្នុងប្រកាសក្រសួងមហាផ្ទៃលេខ ១៨៨៤ ប្រក ចុះថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ២០០២ ដើម្បីជួយគាំទ្រដល់ឃុំ សង្កាត់អនុវត្តឱ្យបានសំរេចនូវសេចក្តីណែនាំនេះ ។

សេចក្តីណែនាំនេះមានប្រសិទ្ធភាពចាប់ថ្ងៃចុះហត្ថលេខា និងឡាយព្រះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែ[illegible] ឆ្នាំ ២០០៦

**ឧបនាយករដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

ស ខេង

ចម្លងជូន

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- គ្រប់ទីស្តីការក្រសួង ស្ថាប័ន នៃរាជរដ្ឋាភិបាល
  "ដើម្បីជូនជ្រាប"
- អគ្គលេខាធិការដ្ឋាន
- អគ្គស្នងការដ្ឋាននគរបាលជាតិ
- អគ្គនាយកដ្ឋានរដ្ឋបាល
- អគ្គាធិការដ្ឋានកិច្ចការនយោបាយ រដ្ឋបាល និងនគរបាល
- គ្រប់សាលាខេត្ត ក្រុង
  "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ